**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន ដឹកនាំគណៈប្រតិភូចម្រុះ
ចុះសាកសួរសុខទុក្ខ ពិធីចុះហត្ថលេខាលើពិធីសារ និងចែកអំណោយស្បៀង គ្រឿងឧបភោគ បរិភោគ
ដល់អង្គភាពសម្ព័ន្ធមេត្រីភាព កងការពារព្រំដែនគោកលេខ៤០២ ភូមិផ្អុង ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ**

ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រី ប្រធានគណៈប្រតិភូចម្រុះ និងតំណាងស្ថានីយទូរទស្សន៍ CTN ព្រមទាំងសហការី ចុះសាកសួរសុខទុក្ខ ពិធីចុះហត្ថលេខាលើពិធីសារ និងចែកអំណោយស្បៀង គ្រឿងឧបភោគ បរិភោគ ដល់អង្គភាពសម្ព័ន្ធមេត្រីភាព កងការពារព្រំដែនគោកលេខ៤០២ នៃយោធភូមិភាគ៤ ខេត្តឧត្តរមានជ័យ នៅថ្ងៃទី ១៨-២០ ខែ កក្កដា ឆ្នាំ ២០១០ ក្នុងពិធីនោះអមដំណើរដោយ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈិន ចំរ្នំពណ៌** ទីប្រឹក្សាផ្ទាល់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេបញ្ជាការរងកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ ប្រធានគណៈបញ្ជាការសមរភូមិទិសទី៣ ប្រចាំសំរោង-ឧត្តរមានជ័យ លោកវរៈសេនីយ៍ឯក **តន់ ញាន** មេបញ្ជាការកងការពារព្រំដែនលេខ៤០២ លោកមេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង ពលទាហានទាំងអស់ ជាសហការីអមដំណើរ ។

នេះជាលើកទី ៦ (ពីរលើកចុងឆ្នាំ២០០៨ ,លើកទី៣ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ , លើកទី៤ ថ្ងៃទី ១១-១៣ ខែ មករា ឆ្នាំ ២០១០ , លើកទី៥ ថ្ងៃទី ០៥-០៦ ខែ មេសា ឆ្នាំ ២០១០ និងថ្ងៃនេះជាលើកទី៦) ដែលគណៈប្រតិភូក្រសួងសាធារណការ និងដឹកជញ្ជូន និងរូបខ្ញុំក្នុងការចុះសាកសួរសុខទុក្ខបងប្អូនយុទ្ធជន ដែលកំពុងឈរជើងប្រតិបត្តិការសឹកនាទិសឧត្តរតាមបណ្តោយព្រំដែនកម្ពុជា-ថៃ នាឱកាសនេះ ។ កាលពីពេលថ្មីៗនេះ គណៈប្រតិភូក្រសួងសាធារណការ និងដឹកជញ្ជូន ដឹកនាំដោយឯកឧត្តម **ត្រាំ អ៊ីវតឹក** និងសហការី បានអមដំណើរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** យឹម ឆៃលី ចំនួនពីរយប់បីថ្ងៃ នៅមុំបី តាមន្ត តាក្របី ថ្មដូន (ថ្ងៃទី ១១-៣ ខែ មករា ឆ្នាំ ២០១០), គណៈប្រតិភូក្រសួងសាធារណការ និងដឹកជញ្ជូន ដឹកនាំដោយឯកឧត្តម **ត្រាំ អ៊ីវតឹក** និងសហការី បានអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាសប្រាំ** ហ៊ុន សែន **និង លោកជំទាវ** នៅព្រំដែនកម្ពុជា-ថៃ (ថ្ងៃទី ០៥-១០ ខែ កុម្ភៈ ឆ្នាំ ២០១០) និងគណៈប្រតិភូ ក្រសួងសាធារណការ និងដឹកជញ្ជូន ដឹកនាំដោយឯកឧត្តម **ត្រាំ អ៊ីវតឹក** និងសហការី បានអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាសប្រាំ** ហ៊ុន សែន **និង លោកជំទាវ** នៅព្រំដែនកម្ពុជា-ថៃ (ថ្ងៃទី ២៦-២៧ ខែ កុម្ភៈ ឆ្នាំ ២០១០) ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង។

ក្រសួងសាធារណការ និងដឹកជញ្ជូន បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការស្តារឡើងវិញ និងការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ការប្រឹងប្រែងក្នុងការអភិវឌ្ឍន៍ផ្លូវថ្នល់ ស្ពាននេះ បានបង្កើតមូលដ្ឋានគ្រឹះក្នុងការការពារទប់ស្កាត់ពីការឈ្លានពានរបស់ប្រទេសជិតខាង ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការកើនឡើងទំហំចរាចរណ៍ និងការផ្លាស់ប្តូរទំនិញនិងទេសចរណ៍ ពិសេសការសាងសង់ស្ពានធំៗឆ្លងកាត់ទន្លេធ្វើអោយហេដ្ឋារចនាសម្ព័ន្ធផ្លូវ ស្ពានមានវឌ្ឍនភាពជារៀងរាល់ថ្ងៃ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ ហើយនូវថ្មីនេះ រាជារដ្ឋាភិបាលជប៉ុន បានផ្តល់នូវជំនួយសម្រាប់សាងសង់ស្ពានអ្នកលឿង ប្រវែង ២,២២០ ម៉ែត្រ ដែលជាស្ពានដ៏វែងសម្រាប់តភ្ជាប់នៅក្នុងប្រទេស និងជាមួយប្រទេសជិតខាង សម្រាប់ជាលំហូរសេដ្ឋកិច្ចមកក្នុងប្រទេស ។

ឯកឧត្តមរដ្ឋមន្ត្រី លើកឡើងនូវសមិទ្ធិផលមួយចំនួនដែលក្រសួងសម្រេចបាន និងសម្ពោធដាក់អោយ ប្រើប្រាស់ជាផ្លូវការរបស់រាជរដ្ឋាភិបាលមានដូចជា ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ស្ពានទូទាំងព្រះរាជាណាចក្រកម្ពុជា មានការរីកចម្រើនគួរជាទីមោទនភាព ពិសេសតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ យើងមានផ្លូវកៅស៊ូ ស្ពានបេតុង បម្រើដល់ការចរាចរណ៍ដឹកជញ្ជូនយ៉ាងឆាប់រហ័ស ។

ក្នុងឱកាសនោះ ឯកឧត្តម **ត្រាំ អ៊ីវតឹក** បានសំដែងការគោរពក្នុងមនោសញ្ចេតនានឹករលឹកដ៏ជ្រាលជ្រៅចំពោះយុទ្ធជន យុទ្ធនារី នៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ដែលកំពុងបំពេញភារកិច្ចការពារជាតិប្រកបដោយវីរៈភាពអង់អាចក្លាហាន នៅទិសប្រាសាទព្រះវិហារ និងគ្រប់តំបន់ផ្សេងៗទៀតនៃមាតុភូមិ ទាំងដែនគោក និងដែនសមុទ្រ ពិសេសកងវិស្វកម្មចំរុះ **(ឯកឧត្តម ខ្វាន់ ស៊ាម , ឯកឧត្តម ខេង សុមេធ, ឯកឧត្តម ប៊ូ ផាន់សារី, ឯកឧត្តម សែម សុវណ្ណនី,**

**ឯកឧត្តម គង់ អៀង)** បាននឹងកំពុងមមាញឹកកសាងផ្លូវខ្សែក្រវ៉ាត់ព្រំដែនជិតរាប់ពាន់គីឡូម៉ែត្រ គួរជាទីមោទនៈក្រៃលែង។ ឯកឧត្តមក៏បានអោយបងប្អូនយកចិត្តទុកដាក់បន្ថែមទៀតក្នុង ការថែរក្សាសុខភាព រស់នៅស្អាត ហូបស្អាត ទឹកស្អាត ស្នាក់អាស្រ័យពេលយប់ សម្រាកនិងគេងត្រូវដាក់មុងការពារ កុំអោយកើតជម្ងឺគ្រុនចាញ់ ជាពិសេសត្រូវមានកម្មវិធីលេងកីឡា ដើម្បីពង្រឹងកាយសម្បទារបស់យើងទាំងអស់គ្នា អោយរឹងមាំ និងភាពរហ័សរហួន ។

ព្រមជាមួយនឹងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្តារ និងសាងសង់ផ្លូវ ស្ពាន បានស្អាតល្អរួចរាល់ ហើយបញ្ហាដែលចោទឡើង គឺការកើនឡើងនៃគ្រោះថ្នាក់ចរាចរណ៍ ដោយសារតែការមិនគោរពច្បាប់ចរាចរណ៍ បើកបរក្នុងល្បឿនលឿន ហើយមិនប្រុងប្រយ័ត្ន ដែលបណ្តាលអោយមានមនុស្សស្លាប់ របួស និងពិការជាច្រើន ពីព្រោះថា កាលពីមុននៅពេលផ្លូវខូច មានស្ថានភាពមិនល្អ មានគ្រលុកច្រើន ចរាចរណ៍លំបាក រថយន្តមានចំនួនតិចតួច បើកបរក្នុងល្បឿនយឺតៗ ហើយគ្រោះថ្នាក់ក៏ពុំសូវមាន ប៉ុន្តែពេលសាងសង់រួច ស្ថានភាពផ្លូវល្អ រថយន្តធ្វើចរាចរណ៍ក៏កើនឡើងច្រើន បើកបរក្នុងល្បឿនលឿន ធ្វើអោយគ្រោះថ្នាក់ក៏កើនឡើង ។ តាមរយៈបងៗយុទ្ធជន សូមជួយប្រាប់បងប្អូនប្រជាពលរដ្ឋដែលរស់នៅតាមដងផ្លូវដែលមានទម្លាប់ចាស់ អោយណែនាំកូនចៅអោយដល់កំរិត ពិសេសពេលឆ្លងផ្លូវត្រូវមើលឆ្វេងស្តាំ ព្រោះពីមុននៅលើផ្លូវមិនទាន់មានឡានបើកបរច្រើននៅឡើយ ដែលអាចបណ្តាលមានគ្រោះថ្នាក់ដល់ជីវិត និងក៏សូមសំណូមពរដល់បងប្អូនយុទ្ធជន និងសូមណែនាំកូនចៅ និងក្មួយៗដែលនៅជុំវិញខ្លួនយើង ដែលប្រើប្រាស់ទោចក្រយានយន្ត គោយន្តគ្រប់ប្រភេទ អោយមានការប្រុងប្រយ័ត្ន និងគោរពច្បាប់ចរាចរណ៍អោយបានខ្ជាប់ខ្ជួន ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ដែលកើតមានឡើងជាយថាហេតុ ។

បន្ទាប់មកក៏មានពិធីចុះហត្ថលេខាលើពិធីសារចងសម្ព័ន្ធមេត្រីភាពរវាងក្រសួងសាធារណការ និងដឹកជញ្ជូន ស្ថានីយទូរទស្សន៍ CTN ជាមួយកងការពារព្រំដែនគោកលេខ៤០២ នៃយោធភូមិភាគ៤ ដើម្បីបង្កើនកិច្ចសហការអោយកាន់តែមានភាពល្អិតរមួតនិងជោគជ័យ អនុវត្តតាមស្មារតីរបស់រាជរដ្ឋាភិបាល ដោយមាន **សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន គឺ **"ការពារដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការពារជាតិ"** អនុវត្តតាមសេចក្តីសម្រេចលេខ១៤ ស.ស.រ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា " ស្តីពីការកែសម្រួល និងរៀបចំការចងសម្ព័ន្ធមេត្រីភាពរវាងអង្គភាពកងទ័ព កងនគរបាលជាតិ ជាមួយ ស្ថាប័ន-អង្គភាពស៊ីវិល " ។ ក្នុងការចងសម្ព័ន្ធមេត្រីភាពជាមួយគ្នា ក្នុងស្មារតីសហប្រតិបត្តិការជិតស្និទ្ធ ជួយគ្នា ទៅវិញទៅមកទាំងស្មារតី និងសម្ភារៈ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អង្គភាពទាំងបី បានព្រមព្រៀងដាក់ចេញនូវពិធីសារ ដែលមានខ្លឹមសារ៤ចំណុច គន្លឹះសម្រាប់ដំណើរការប្រតិបត្តិឱ្យបានជោគជ័យរវាងការ ផ្សាភ្ជាប់សមរភូមិមុខ និងសមរភូមិក្រោយកាន់តែល្អប្រពៃបន្ថែមទៀត ។

ស្របជាមួយគ្នានេះដែរ គណៈប្រតិភូចម្រុះ ក្រសួងសាធារណការនិងដឹកជញ្ជូន ស្ថានីយទូរទស្សន៍ CTN បានរៀបចំប្រគល់នូវគ្រឿងឧបភោគ និងបរិភោគ ជូនដល់បងប្អូនយុទ្ធជន មានដូចខាងក្រោម :

១. ផ្លូវក្រាលគ្រួសក្រហមចំនួន០២ខ្សែ ក្នុងភូមិសាស្ត្រអង្គភាពកងការពារព្រំដែនគោកលេខ៤០២
២. ថវិកា **ចំនួន ២០,០០០,០០០ រៀល**
៣. ស៊ីទែនទឹកដែកអ៊ីណុក ចំណុះ ៥,០០០ លីត្រ **ចំនួន ០២ គ្រឿង**
៤. GPS ម៉ាក GARMIN CSX **ចំនួន ០១ គ្រឿង**
៥. វិទ្យុទាក់ទងម៉ាកវ៉ៃវ៉ៃ ៣២៨៨ **ចំនួន ១៥ គ្រឿង**
៦. ម៉ាស៊ីនភ្លើងម៉ាក YANDONG **ចំនួន ០១ គ្រឿង**
៧. ប្រេងម៉ាស៊ូត **ចំនួន ៤០០ លីត្រ**
៨. មីយើង **ចំនួន ៥០ កេស**
៩. ទឹកត្រីសញ្ញាត្រីប្រាំ **ចំនួន ៥០ យួរ**
១០. ទឹកស៊ីអ៊ីវសញ្ញាទាទឹម **ចំនួន ៥០ យួរ**
១១. ទឹកសុទ្ធសញ្ញាផ្កាម្លិះ **ចំនួន ២០០ យួរ**
១២. ត្រីងៀត **ចំនួន ៤០ គីឡូក្រាម**
១៣. អង្ករនាងមិញ **ចំនួន ១០០ បាវ**

១៤. ប្រេងកូឡាសញ្ញាតាប៉ិ **ចំនួន ៤០ ឡូ**

១៥. ថ្នាំពេទ្យ **ចំនួន ៩០០ កញ្ចប់**

ជាទីបញ្ចប់ នៅក្នុងឱកាសរីករាយនិងស្និទ្ធស្នាលនេះ ក្នុងនាមគណៈប្រតិភូចម្រុះ ឯកឧត្តម **ត្រាំ អ៊ីវតឹក** បានជូនពរ ឯកឧត្តម អស់លោក មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង ពលទាហានទាំងអស់គ្រប់អង្គភាព សូមប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ពិសេសសូមបងប្អូនយុទ្ធជនទាំងអស់ សំរេចនូវរាល់ភារកិច្ចក្នុងការការពារប្រទេសពីការរំលោភឈ្លានពានរបស់ប្រទេសជិតខាង និងបងប្អូនគ្រួសារយុទ្ធជន ដែលចូលរួមក្នុងពិធីនេះ សូមប្រកបដោយដោយសេចក្ដីសុខគ្រប់ប្រការ និងជោគជ័យ គ្រប់ភារកិច្ច ។